# គោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧

# មាតិកា

១. ចក្ខុវិស័យ, គោលបំណង, និងគោលដៅ

២. យុទ្ធសាស្ត្រ

២.១ វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ

២.២ វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង

៣. ការរៀបចំនីតិវិធីប្រតិបត្តិការរួម និងគោលការណ៍ណែនាំគម្រោង PPP

៤. ការពិនិត្យ និងវាយតម្លៃសំណើគម្រោងតាមយន្តការ PPP

៥. ដំណើរការនៃការស្នើគម្រោងតាមយន្តការ PPP

# ១. ចក្ខុវិស័យ

*«នៅមុនដំណាច់ឆ្នាំ២០២០ រាជរដ្ឋាភិបាលត្រូវបង្កើត និង អនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការ PPP ប្រកបដោយភាពប្រទាក់ក្រឡានិងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រង ហានិភ័យនៃកាតព្វកិច្ចបំណុលដាយថាហេតុដែលកើតចេញពីការ អនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការនេះ។»*

# ១. គោលបំណង និងគោលដៅ (ត)

## គោលបំណង

*«ជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការចូលរួមសា្ថរ, កសាង, ដួសជុល, ប្រតិបត្តិការ, និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក។»*

# ១. គោលបំណង និងគោលដៅ(ត)

## គោលដៅ

*«ដាក់ចេញនូវយុទ្ធសាស្ត្រ, កំណត់យន្តការស្ថាប័ន, និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការ PPP ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់-ក្រឡាគ្នា ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលផាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។»*

# ២. យុទ្ធសាស្ត្រ

- យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការរៀបចំ និងដាក់ចេញនូវ **វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និងសម្រាប់រយៈពេលមធ្យមនិងវែង** ដោយនឹងត្រូវអនុវត្តតាមអភិក្រម ជាជំហានៗ រួមមាន៖

  (១) ការចាប់ផ្តើមចេញពីការពិនិត្យនិងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្ត, ការដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ការបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ, និងការកំណត់យន្តការស្ថាប័ន ព្រមទាំងបង្កើតគណៈកម្មការអន្តរក្រសួង ជាស្ថាប័នបណ្តោះអាសន្ន សម្រាប់គ្រប់គ្រង និងសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រនេះ

  (២) អភិក្រម **"រៀនផង-ធ្វើផង"**

  (៣) ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស តាមក្រសួង ស្ថាប័នពាក់ព័ន្ធ។

# ២.១ វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ

១. បង្កើតគណៈកម្មការអន្តរក្រសួងបណ្ដោះអាសន្ន ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធដែលមានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្ដីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងធ្វើសំណើសុំវិសោធនកម្ម ឬ សំណើសុំរៀបចំសេចក្ដីព្រាងច្បាប់ថ្មីស្ដីពីយន្តការ PPP តាមការចាំបាច់។
- រៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, នីតិវិធីគ្រប់គ្រងកិច្ចលទ្ធកម្ម, នីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុ។ល។
- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាពតាមយន្តការ PPP និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពតាមគោលការណ៍ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព, តម្លាភាព, យុត្តិធម៌ និងដោយមានការផ្សព្វផ្សាយជាសាធារណៈ។

មុខងារ និងភារកិច្ចទាំងនេះ នឹងត្រូវផ្ទេរជូនយន្តការអចិន្ត្រៃយ៍ដែលនឹងត្រូវពិនិត្យ និងសម្រេចដោយរាជរដ្ឋាភិបាល។

# ២.១ វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ (ត)

គណៈកម្មការអន្តរក្រសួងនេះ មាន **ក្រុមការងារបច្ចេកទេស** សម្របសម្រួលការអនុវត្តគោលនយោបាយ PPP ជា **លេខាធិការដ្ឋាន** ដែលមានភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួល និងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគតាមយន្តការ PPP ។
- ផ្តល់ការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចចុះកិច្ចសន្យា ជាមួយដៃគូឯកជន ក្នុងការកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងការអនុវត្តគម្រោង។
- ពិនិត្យ និងតាមដានលើកិច្ចប្រតិបត្តិនៅគ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោងវិនិយោគតាមយន្តការ PPP ។
- ផ្តល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងលើការអនុវត្ត និងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការ PPP។
- គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់គាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារសិក្សា និងការរៀបចំគម្រោង ព្រមទាំងប្រតិបត្តិការនានាដើម្បីឈានដល់ការប្រគល់កិច្ចសន្យាអនុវត្តគម្រោងតាមយន្តការ PPP។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួង។
- បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់ប្រធានគណៈកម្មការអន្តរក្រសួង។

# ២.១ ទិសដៅគោលនយោបាយបន្ទាន់ចំពោះមុខ (ត)

២. បង្កើត និងដាក់ឱ្យអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility - PDF) សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការរៀបចំគម្រោង ដោយគិតចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពបឋម រហូតដល់ដំណាក់កាលប្រគល់កិច្ចសន្យាសម្បទាន។

៣. រៀបចំ និងកំណត់យន្តការស្ថាប័ន ដោយៈ

- ធ្វើសមាហរណកម្មមុខងារនៃអង្គភាព PPP ថ្នាក់កណ្តាល និងអង្គភាពគ្រប់គ្រងហានិភ័យ ទៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បង្កើត ឬធ្វើសមាហរណកម្មមុខងារនៃអង្គភាព PPP នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យ។

៤. ត្រូវផ្តោតលើគម្រោងអាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចខ្ពស់មួយចំនួនសិន ដោយត្រូវអនុវត្តតាមទម្រង់ "**ការទូទាត់ផ្អែកលើផលចំណូល**"។

៥. រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ។

# ២.២ ទិសដៅការគោលនយោបាយរយៈពេលមធ្យម និងវែង

១. បន្តពិនិត្យ និងកែសម្រួលឡើងវិញ តាមការចាំបាច់នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ, យន្តការស្ថាប័ន, នីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុនិងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ។

២. ពិនិត្យលទ្ធភាពលើការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តនូវមូលនិធិបំពេញផលហិរញ្ញវត្ថុ (Viability Gap Fund – VGF)។

៣. ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

៤. ពិនិត្យលទ្ធភាពបង្កើនចំនួនគម្រោង និងពិចារណាលើការអនុវត្តទម្រង់ទូទាត់ផ្សេងទៀត ដូចជា "**ការទូទាត់ផ្អែកលើថវិកាជាតិ**" និង "**ការទូទាត់តាមវិធីចម្រុះ**" ។

# ៣.២ វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង (ត)

- ជាមួយគ្នានេះ ត្រូវធ្វើបច្ចុប្បន្នកម្មលើបញ្ជីគម្រោងអាទិភាព ដោយនឹងពិនិត្យលទ្ធភាពឈានទៅបន្ថែមវិស័យអាទិភាពមួយចំនួនទៀត រួមមាន៖
    - o ហេដ្ឋារចនាសម្ព័ន្ធវិស័យឧស្ម័ន និងប្រេងកាត
    - o វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
    - o ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រនិងកសិកម្ម និង
    - o វិស័យអាទិភាពដទៃទៀត។
- សម្រាប់រយៈពេលវែង អាចនឹងឈានទៅពិនិត្យលទ្ធភាពលើការវិនិយោគក្នុងវិស័យសង្គមកិច្ចបន្ថែមទៀត ដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធសេវាសុខភាពសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធអប់រំ និងកីឡា ជាដើម។

# ៣. ការរៀបចំនីតិវិធីប្រតិបត្តិការរួម និងគោលការណ៍ណែនាំគម្រោង PPP

- ដើម្បីរៀបចំ និងអនុវត្តគម្រោងតាមយន្តការ PPP ឱ្យស្របតាមដំណាក់កាល ដែលអនុវត្តជាអន្តរជាតិ ក្រុមការងារបច្ចេកទេស សហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី បានកំពុងរៀបចំនីតិវិធីប្រតិបត្តិការរួម និងគោលការណ៍ណែនាំគម្រោង PPP ដូចខាងក្រោម៖

<table>
<tr><th colspan="4">នីតិវិធីប្រតិបត្តិការរួម (SOP)</th></tr>
<tr><th>ដំណាក់កាលជ្រើសរើសគម្រោង</th><th>ដំណាក់កាលសិក្សាសិទ្ធិលទ្ធភាព</th><th>ដំណាក់កាលកិច្ចលទ្ធកម្ម និងចុះកិច្ចសន្យា</th><th>ដំណាក់កាលគ្រប់គ្រងកិច្ចសន្យា</th></tr>
<tr><td>គោលការណ៍ណែនាំស្តីពីការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើសគម្រោង</td><td rowspan="4">គោលការណ៍ណែនាំស្តីពីការសិក្សាសិទ្ធិលទ្ធភាព</td><td rowspan="2">គោលការណ៍ណែនាំស្តីពីនីតិវិធីកិច្ចលទ្ធកម្ម មាន ០៤ ផ្នែក។</td><td rowspan="2">គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងកិច្ចសន្យា</td></tr>
<tr><td>គោលការណ៍ណែនាំស្តីពីមូលនិធិអភិវឌ្ឍន៍គម្រោង</td></tr>
<tr><td>ផ្នែកទី១៖ ការបុរេជ្រើសរើសក្រុមទីប្រឹក្សាប្រតិបត្តិការ (Pre-qualified Panel of Advisors)</td><td>ផ្នែកទី៤៖ ការជ្រើសរើសដៃគូឯកជន (Private Proponent)</td><td rowspan="3">ផ្នែកទី៣៖ ការជ្រើសរើសទីប្រឹក្សាឯករាជ្យ (Independent Consultant)</td></tr>
<tr><td rowspan="2">ផ្នែកទី២៖ ការជ្រើសរើសទីប្រឹក្សាប្រតិបត្តិការ (Transaction Advisors)</td><td>គោលការណ៍ណែនាំស្តីពីគំរូកិច្ចសន្យាសម្បទាន</td></tr>
<tr><td colspan="2">គោលការណ៍ណែនាំស្តីពីការបំពេញផលចំណេញហិរញ្ញវត្ថុ (Viability Gap Fund)</td></tr>
</table>

# ៤. ការពិនិត្យ និងវាយតម្លៃសំណើគម្រោងតាមយន្តការ PPP

- ការវាយតម្លៃគម្រោង PPP តាមគោលការណ៍ណែនាំការធ្វើអត្តសញ្ញាណកម្ម និងជ្រើសរើស គឺបែងចែកជា ២ ដំណាក់កាល៖
  - **ដំណាក់កាលទី១៖** គឺជាដំណាក់កាល "ដាប់/ធ្លាក់" ដែលមានលក្ខខណ្ឌវិនិច្ឆ័យចំនួន ០៧។
  - **ដំណាក់កាលទី២៖** គឺជាដំណាក់កាលដាក់ពិន្ទុ និងចំណាត់ថ្នាក់គម្រោង ទៅតាមលក្ខខណ្ឌវិនិច្ឆ័យចំនួន ០៦។

# ៤. ការពិនិត្យ និងវាយតម្លៃសំណើគម្រោងតាមយន្តការ PPP (ត)

- **<u>ដំណាក់កាលទី១៖</u>** "ដាប់/ធ្លាក់"

១. គម្រោងស្របតាមអាទិភាពជាយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

២. គម្រោងមានទំហំទុនវិនិយោគអប្បបរមា ១០ លានដុល្លារអាមេរិក

៣. គម្រោងមានការគាំទ្រពីបណ្តាភាគីពាក់ព័ន្ធ ដោយផ្អែកលើការធ្វើពិគ្រោះយោបល់បឋម

៤. ក្រសួង ស្ថាប័នម្ចាស់សំណើគម្រោងមានឆន្ទៈក្នុងការអនុវត្តគម្រោង ដោយផ្តល់ការបញ្ជាក់ជាលាយលក្ខអក្សរ

៥. គម្រោងមិនត្រូវការចំណាយខ្ពស់លើការដោះស្រាយផលប៉ះពាល់ដីធ្លី បរិស្ថាន និងសង្គម

៦. លទ្ធផលយថាប្រភេទ (Output Specification) និងយន្តការទូទាត់ ត្រូវបានកំណត់ច្បាស់លាស់

៧. គម្រោងប្រហាក់ប្រហែលនឹងសំណើគម្រោង ធ្លាប់បានធ្វើកិច្ចលទ្ធកម្មពីមុនមក។

**<u>រាល់សំណើគម្រោងណាដែលមិនអនុលោមតាមលក្ខខណ្ឌវិនិច្ឆ័យណាមួយខាងលើ គឺត្រូវវាយតម្លៃឱ្យធ្លាក់ និងមិនអាចបន្តទៅដំណាក់កាលទី២។</u>**

# ៤. ការពិនិត្យ និងវាយតម្លៃសំណើគម្រោងតាមយន្តការ PPP (ត)

- **<u>ដំណាក់កាលទី២៖</u>** “ការដាក់ពិន្ទុ”

១. ការទទួលយករបស់ទីផ្សារ (Market Acceptability)

២. យន្តការប្រមូលចំណូលអាចប៉ាន់ស្មានបាន និងមានភាពទាក់ទាញផ្នែកហិរញ្ញវត្ថុ

៣. ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម (Economic and Social Desirability)

៤. ការបែងចែកហានិភ័យសមស្រប

៥. ចំណាយក្នុងមួយវដ្តគម្រោងចាប់ពីការវិនិយោគ ប្រតិបត្តិការ និងថែទាំអាចប៉ាន់ស្មានបាន

៦. អនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តដែលមានជាធរមាន

**<u>រាល់គម្រោងណាដែលទទួលបានពិន្ទុសរុបចាប់ពី ៧០% ឡើងទៅ ត្រូវវាយតម្លៃឱ្យជាប់ និងបន្តធ្វើអាទិភាពរូបនីកម្មគម្រោង ឬចំណាត់ថ្នាក់ទៅតាមលទ្ធផលនៃការវាយតម្លៃ។</u>**

# ៦. ដំណើរការនៃការស្នើគម្រោងតាមយន្តការ PPP (បច្ចុប្បន្ន - Indicative)

**ដំណាក់កាលទី១**

- ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដាក់សំណើគម្រោងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងវាយតម្លៃ។
- ក្នុងករណីវិស័យឯកជនស្នើគម្រោង គឺត្រូវធ្វើឡើងតាមរយៈក្រសួង ស្ថាប័នតាមវិស័យ ដើម្បីដាក់សំណើគម្រោងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ដំណាក់កាលទី២**

- គណៈកម្មការអន្តរក្រសួងដឹកនាំការងារ PPP នឹងពិនិត្យ និងសម្រេចថាតើសំណើគម្រោងអាចបន្តដល់ដំណាក់កាលសិក្សាសមិទ្ធលទ្ធភាព (F/S)។
- ក្នុងករណីបន្ត ក្រសួង ស្ថាប័នម្ចាស់សំណើគម្រោងអាចជួល Transaction Advisors ដើម្បីធ្វើ F/S ដោយស្នើសុំហិរញ្ញប្បទានពី PDF។
- គណៈកម្មការអន្តរក្រសួងដឹកនាំការងារ PPP នឹងពិនិត្យលើលទ្ធផលនៃការសិក្សាលទ្ធភាព ថាតើនឹងបន្តទៅដំណាក់កាលកិច្ចលទ្ធកម្ម។

**ដំណាក់កាលទី៣**

- ក្រសួង ស្ថាប័នម្ចាស់សំណើគម្រោងនឹងដឹកនាំកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន ឬសម្បទានិក ដោយមានការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ចុះកិច្ចសន្យាជាមួយដៃគូឯកជន ឬសម្បទានិក។

# សូមអរគុណ